**Speech by Mr. YONAMINE Moriyasu**
**Second Secretary of the Embassy of Japan in the Kingdom of Cambodia**
**At the Inauguration Ceremony of**
**Khun Ream Health Center in Banteay Srey District, Siem Reap Province**

**March 13, 2015**

- Venerable Monks,
- H.E. Dr. Te Kuy Seang, Secretary of State Ministry of Health,
- H.E. Dr. Sang Riha, Vice Governor, Siem Reap Province,
- Mr. Andrew Hill, Deputy Country Director of Plan International Cambodia,
- Dr. Kros Sarath, Director of Provincial Health Department in Siem Reap Province,
- Ladies and Gentlemen,

It is a great pleasure for me to attend the Inauguration ceremony of the project for constructing Khun Ream Health Center in Banteay Srey District, Siem Reap Province, with the presence of H.E. Dr. Te Kuy Seang, Secretary of Ministry of Health. First of all, I would like to express my sincere gratitude to H.E. Dr. Te Kuy Seang, Secretary of Ministry of Health, Plan International Cambodia’s staff and all those who attend this ceremony.

The improvement in healthcare is one of the most important reformation by the Government of Cambodia under the Rectangular Strategy Ⅲ, which has made steady progress. The Government of Japan has been supporting the Government of Cambodia’s effort for the improvement in healthcare through developing human resources and improving the circumstances of medical care facilities including the construction of National Maternal & Child Health Centre through grand aid.

The project is to construct a health center and install a medical incinerator and medical beds in Banteay Srey district, Siem Reap province. The project aims to allow about 6,400 residents in the region, where is located 10 km away from the nearest health center, to receive better medical treatment in safer and more attentive environment, and thus it is expected to contribute the health improvement in the region.

I strongly hope that Khun Ream Health Center will expand further health service delivery in Siem Reap province and, consequently, many residents will benefit from better medical services provided by the health center.

Finally, I sincerely hope that the health center will be maintained properly and utilized effectively over a long period of time as a symbol of friendly relations between Cambodian and Japanese people.

Thank you very much for your attention.

**សុន្ទរកថារបស់លោក យូណាមីណិ ម៉ូរីយ៉ាស៊ូ**
**លេខាទី២ នៃស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**
**ថ្លែងក្នុងពិធីសម្ពោធមណ្ឌលសុខភាពឃុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប**
**ថ្ងៃទី១៣ ខែមិនា ឆ្នាំ ២០១៥**

- សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ
- H.E. Dr. Te Kuy Seang, Secretary of Ministry of Health,
- H.E. Dr. Sang Riha, Deputy Provincial Governor,
- សូមគោរព លោកវេជ្ជៈបណ្ឌិត គ្រួស សារ៉ាត់ ប្រធានមន្ទីរសុខាភិបាលខេត្តសៀមរាប
- Mr. Andrew Hill, Deputy Country Director of Plan International Cambodia,
- សូមគោរព អស់លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់!

ខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែង ដែលបានចូលរួមក្នុងពិធីសម្ពោធគម្រោងសម្រាប់ការសាងសង់ណ្ឌលសុខភាពឃុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមានវត្តមានដ៏ខ្ពង់ខ្ពស់របស់ H.E. Dr. Te Kuy Seang, Secretary of Ministry of Health ។ ជាបឋម ខ្ញុំសូមសំដែងនូវការដឹងគុណដ៏ជ្រាលជ្រៅដល់ H.E. Dr. Te Kuy Seang, Secretary of Ministry of Health និងបុគ្គលិកអង្គការផ្លែនអន្តរជាតិ-កម្ពុជា ព្រមទាំងភ្ញៀវកិត្តិយសទាំងអស់ដែលបានចូលរួមក្នុងពិធីនេះ។

ការពង្រឹងផ្នែកសុខាភិបាល គឺជាការកំណែទម្រង់មួយដ៏សំខាន់នៃបណ្តាកំណែទម្រង់ដទៃទៀត ដែលបានធ្វើអោយមានការរីកចម្រើនជាលំដាប់ ស្របតាមយុទ្ធសាស្រ្តចតុកោណដំណាក់កាលទីបីរបស់រាជរដ្ឋាភិបាលកម្ពុជា។ រដ្ឋាភិបាលជប៉ុនបាននឹងកំពុងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការពង្រឹងផ្នែកសុខាភិបាល តាមរយៈការអភិវឌ្ឍធនធានមនុស្ស និងការកែលម្អស្ថានភាពមណ្ឌលសុខភាពថែទាំវេជ្ជសាស្រ្តរួមមាន ការសាងសង់មជ្ឈមណ្ឌលមាតាជាតិនិងកុមារ តាមរយៈការជំនួយឥតសំណង។

គម្រោងនេះ គឺដើម្បីសាងសង់មណ្ឌលសុខភាព ព្រមទាំងបំពាក់សម្ភារៈសុខាភិបាលរួមមាន មីក្រូទស្សន៍មួយ និងគ្រែអ្នកជម្ងឺចំនួន៩ ក្នុងស្រុកបន្ទាយស្រី ខេត្តសៀមរាប។ គម្រោងនេះ មានគោលបំណងអោយប្រជាជនក្នុងតំបន់ប្រមាណ ៦,៤០០នាក់ ដែលមានទីតាំងចំងាយ១០គីឡូម៉ែត្រពីមណ្ឌលសុខភាពដែលនៅជិតបំផុត ទទួលបានការព្យាបាលអោយកាន់តែមានសុវត្ថិភាព និងមានការយកចិត្តទុកដាក់ខ្ពស់ ហើយគម្រោងនេះត្រូវបានរំពឹងថា នឹងចូលរួមចំណែកជួយសម្រាលស្ថានភាពសុខភាពនៅក្នុងតំបន់។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា មណ្ឌលសុខភាពឃុនរាមនេះ នឹងពង្រីកការផ្តល់សេវាសុខាភិបាលក្នុងខេត្តសៀមរាបបន្តទៅទៀត ហើយជាលទ្ធផលប្រជាពលរដ្ឋជាច្រើននឹងបានទទួលអត្ថប្រយោជន៍ពីសេវាសុខាភិបាលកាន់តែល្អប្រសើរ ដែលផ្តល់ដោយមន្ទីរពេទ្យ។

ជាចុងក្រោយ ខ្ញុំសង្ឃឹមដោយស្មោះសរថាមណ្ឌលសុខភាពនេះ នឹងត្រូវបានថែទាំយ៉ាងត្រឹមត្រូវនិងប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាពជាយូរអង្វែង ដើម្បីទុកជានិមិត្តរូបនៃទំនាក់ទំនងមិត្តភាពរវាងប្រជាជន ជប៉ុននិងប្រជាជនកម្ពុជា។

**សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់។**